# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាអគ្គសញ្ញាលាបថ្វាស
## បឹងទំពុន ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩
## ទទួលព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ

**អត្ថបទទី១៖ សុភាសិត ៨,២២-៣១**

ព្រះអង្គបានចាក់ប្រេងតែងតាំងខ្ញុំ តាំងពីអស់កល្បរៀងមកគឺនៅគ្រាដំបូងបង្អស់ មុនកំណើតពិភពលោកទៅទៀត។ សុភ ៨,២៣

**អត្ថបទទី២៖ រ៉ូម ៥,១-៥**

មិនតែប៉ុណ្ណោះសោត នៅពេលយើងរងទុក្ខវេទនា យើងនៅតែខ្ពស់មុខដដែល ព្រោះយើងដឹងថា ទុក្ខវេទនានឹងនាំឲ្យយើងចេះអត់ធ្មត់ ការអត់ធ្មត់នាំឲ្យយើងចេះស៊ូទ្រាំ ហើយការស៊ូទ្រាំនាំឲ្យយើងមានសេចក្ដីសង្ឃឹម។ រម ៥,៣-៤

**ដំណឹងល្អ៖ យ៉ូហាន ១៦,១២-១៥**

កាលណាព្រះវិញ្ញាណនៃសេចក្ដីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាឲ្យស្គាល់សេចក្ដីពិតគ្រប់ចំពូក ដ្បិតសេចក្ដីផ្សេងៗដែលព្រះអង្គថ្លែង មិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្ដីណាដែលទ្រង់ព្រះសណ្ដាប់ឮ ព្រមទាំងមានព្រះបន្ទូលប្រាប់ឲ្យអ្នករាល់គ្នាដឹងអំពីហេតុការណ៍ដែល ត្រូវកើតមាននៅថ្ងៃមុខផង។ យហ ១៦,១៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពបុណ្យព្រះត្រៃឯក ដែលមានព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាអង្គតែមួយ។ ថ្ងៃនេះ យើងមានកិត្តិយសដោយសារព្រះជាម្ចាស់ណែនាំឲ្យយើងចូលនៅក្នុងព្រះជន្មផ្ទាល់របស់ព្រះអង្គ ដើម្បីឲ្យយើងមានបទពិសោធអំពីព្រះអង្គនៅក្នុងជីវិតរបស់យើងផ្ទាល់។ ព្រះជាម្ចាស់ បានបង្កើតយើងទាំងអស់ឲ្យយើងទាំងអស់មានជីវិត ព្រះអង្គបានចាត់ព្រះបុត្រាឲ្យយាងមកដើម្បីណែនាំឲ្យយើងស្គាល់ព្រះបិតា។ ជារៀងរាល់ពេលដែលយើងស្ដាប់ដំណឹងល្អ គឺយើងស្ដាប់ព្រះបន្ទូលដែលចេញពីបបូរមាត់របស់ព្រះយេស៊ូ ដែលជាបុត្រាជាទីស្រឡាញ់របស់ព្រះបិតា។ ថ្ងៃនេះ នៅក្នុងអត្ថបទគម្ពីរដំណឹងល្អគឺព្រះយេស៊ូប្រទានឲ្យយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាអង្គតែមួយ ព្រះវិញ្ញាណដ៏វិសុទ្ធជាដង្ហើមរបស់ព្រះជាម្ចាស់ ជាសេចក្ដីស្រឡាញ់យ៉ាងពិសេសរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានណែនាំឲ្យយើងចូលនៅក្នុងជីវិតពិសេសនេះ ដោយទទួលព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់។ ព្រះជាម្ចាស់យាងមកថ្ងៃនេះ សណ្ឋិតលើបងប្អូនទាំងអស់ឲ្យយើងចូលនៅក្នុងជីវិតដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

អត្ថបទទីពីរ "**ព្រះជាម្ចាស់ចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើងដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង**" ព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។ ថ្ងៃនេះ ដើម្បីឲ្យយើងមានសេចក្ដីក្លាហាន ដើម្បីឲ្យយើងមានជំនឿរឹងមាំ ដើម្បីឲ្យយើងទៅជាគ្រីស្តបរិស័ទសកម្ម ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតពិសេសនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ថ្ងៃនេះយើងទទួលព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងពោរពេញដោយកម្លាំងថ្មី ក្នុងអត្ថបទទីពីរ "**ទុក្ខវេទនានឹងនាំឲ្យយើងចេះអត់ធ្មត់ ការអត់ធ្មត់នាំឲ្យយើងចេះស៊ូទ្រាំ ស៊ូទ្រាំនាំឲ្យយើងមានសេចក្ដីសង្ឃឹមដោយសារយើងមានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់**"។ យើងរៀងៗខ្លួន ប៉ុន្មានដងយើងមានទុក្ខវេទនានៅក្នុងជីវិតរបស់យើង ប៉ុន្មានដងយើងមានទុក្ខលំបាក ប៉ុន្មានដងយើងមានការឈឺចាប់ មានរឿងជាច្រើនដែលណែនាំឲ្យយើងមានទុក្ខវេទនា។ យើងដឹងថា ដោយសារព្រះយេស៊ូសោយទិវង្គតលើឈើឆ្កាងទុក្ខវេទនានោះណែនាំឲ្យយើងមានការអត់ធ្មត់ និងការអត់ធ្មត់ណែនាំឲ្យយើងចេះតស៊ូ ការតស៊ូរបស់យើងណែនាំឲ្យយើងជោគជ័យ ដោយសារយើងរកឃើញសេចក្ដីសង្ឃឹមនៅក្នុងជីវិតយើង ដើម្បីធ្វើជាពន្លឺនៃព្រះជាម្ចាស់ដែលពោរពេញដោយសេចក្ដីស្រឡាញ់ និងណែនាំឲ្យបងប្អូនឯទៀតៗស៊ូទ្រាំនៅក្នុងជីវិត និងរកឃើញសេចក្ដីសង្ឃឹមទៀត។

ទោះបីយើងក្មេងក្ដីចាស់ក្ដី យើងត្រូវតែមានសុបិនសម្រាប់អនាគតយើងដូច្នេះយើងស្ដាប់ដំណឹងល្អនេះ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងទទួលសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងសេចក្ដីស្រឡាញ់នេះណែនាំឲ្យយើងឈ្នះទុក្ខវេទនា ឲ្យយើងមានចិត្តអត់ធ្មត់ ឲ្យយើងស៊ូទ្រាំបាន និងឲ្យយើងពោរពេញដោយសេចក្ដីសង្ឃឹម។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទទួលថ្ងៃនេះ ដើម្បីទៅមុខនៅក្នុងជីវិតដោយដឹងថាព្រះជាម្ចាស់គង់នៅ ព្រះជាម្ចាស់ធ្វើដំណើរជាមួយយើងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធដែលជាដង្ហើមផ្ទាល់របស់ព្រះជាម្ចាស់។

អត្ថបទគម្ពីរដំណឹងល្អ "**កាលណាព្រះវិញ្ញាណនៃសេចក្ដីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាឲ្យស្គាល់សេចក្ដីពិតគ្រប់ជំពូក**"។ វិញ្ញាណនៃសេចក្ដីពិត ណែនាំឲ្យយើងស្គាល់សេចក្ដីពិត សេចក្ដីពិតគឺព្រះយេស៊ូដូចព្រះអង្គមានព្រះបន្ទូលថា "**ខ្ញុំជាផ្លូវ ខ្ញុំជាជីវិត និងខ្ញុំជាសេចក្ដីពិត**"។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងស្គាល់ព្រះយេស៊ូច្បាស់ទៅៗ ជាពិសេសឲ្យយើងនឹកឃើញព្រះយេស៊ូនឹងព្រះបុត្រាជាអង្គតែមួយ ដែលភ្ជាប់គ្នាជាធ្លុងតែមួយណែនាំឲ្យយើងទាំងអស់ដែលជាគ្រីស្តបរិស័ទបង្កើតគ្រួសារតែមួយ។ គ្រួសារតែមួយដែលចេះសហការគ្នា គ្រួសារតែមួយដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក គ្រួសារតែមួយដែលយើងដឹងថាយើងអាចទីពឹងលើគ្នា

ទៅវិញទៅមកបាន។ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ មានចិត្តរាក់ទាក់នៅក្នុងគ្រួសារតែមួយដែលចេះជួយគ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមក ផ្តល់កម្លាំងឲ្យគ្នាទៅវិញទៅមក។ ថ្ងៃនេះ នៅពេលយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៃសេចក្តីពិត ណែនាំឲ្យព្រះសហគមន៍របស់យើងទៅជាគ្រួសារមួយ។ សហការគ្នា យើងជាបព្វជិតបព្វជិតាឲ្យយើងចេះសហការគ្នា លោកបូជាចារ្យនិងលោកអភិបាលឲ្យយើងចេះសហការគ្នា យើងជាគ្រីស្តបរិស័ទឲ្យយើងចេះសហការគ្នាដូចគ្រួសារដ៏សុខសាន្ត។

អត្ថបទទីមួយ "**នៅពេលក្រុមគ្រីស្តទូតបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ គេចាប់ផ្តើមថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់**"។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងគេថ្លែងស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ សម្រាប់យើងក៏ដូចគ្នាដែរឲ្យយើងថ្លែងអំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ នៅក្នុងជីវិតខ្ញុំ **តើខ្ញុំបានទទួលអ្វីដ៏អស្ចារ្យពីព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ?** ប្រសិនបើយើងមិនចេះបើកភ្នែក ធ្វើដូចម្តេចយើងអាចថ្លែងអំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់ យើងបានទទួលជីវិត យើងបានទទួលសេចក្តីសង្ឃឹម។ ពីមួយថ្ងៃទៅមួយថ្ងៃ ព្រះជាម្ចាស់បានប្រទានឲ្យយើងច្រើនណាស់ ឲ្យយើងមើលស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដើម្បីថ្លែងអំពីស្នាព្រះហស្តនេះ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងថ្លែងអំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់ដោយយកចិត្តទុកដាក់។ សម្រាប់យើងជាគ្រីស្តបរិស័ទកម្ពុជា ឲ្យយើងធ្វើជាផ្កាពិសេសសម្រាប់ជីវិតរបស់យើង ដែលណែនាំឲ្យបងប្អូនឯទៀតៗអាចទទួលអត្ថន័យនៃជីវិតថ្មី។ ឲ្យយើងគិត យើងបានថ្លែងអំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់មកពីបទពិសោធយើងជាមួយព្រះអង្គ ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗអាចមានសេចក្តីសង្ឃឹមនៅក្នុងជីវិត។

ថ្ងៃនេះ យើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលជាដង្ហើម ដែលជាអ៊ុកស៊ីសែនពិសេសមកពីព្រះជាម្ចាស់ ដែលណែនាំឲ្យយើងមានជីវិត។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងធ្វើដូចម្តេចដើម្បីឲ្យយើងទទួលព្រះពន្លឺពីព្រះជាម្ចាស់ ព្រះជាម្ចាស់ជាព្រះអាទិត្យយ៉ាងពិសេសដែលណែនាំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងចូល ឲ្យយើងពោរពេញដោយដង្ហើមដែលមានអ៊ុកស៊ីសែនយ៉ាងខ្ពស់ដើម្បីថ្លែងអំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ដើម្បីទទួលព្រះអាទិត្យពីព្រះជាម្ចាស់បាន យើងត្រូវការអធិដ្ឋាន ស្តាប់ព្រះបន្ទូល ចូលអភិបូជា ដោយសារព្រះអាទិត្យរបស់ព្រះជាម្ចាស់បានណែនាំព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឲ្យយើងមានកម្លាំង យើងអាចទៅថ្លែងនិងផ្តល់សក្ខីភាពដល់បងប្អូនឯទៀតៗនៅក្នុងរបៀបសាមញ្ញធម្មតា ដើម្បីឲ្យព្រះសហគមន៍របស់យើងរីកចម្រើនថែមទៀត។

យើងអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យយើងចូលនៅក្នុងក្រុមគ្រួសាររបស់ព្រះអង្គ ដែលជាអង្គតែមួយ គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ឲ្យយើងអធិដ្ឋាន ទូលអង្វរព្រះជាម្ចាស់ពិតមែនសូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ អាម៉ែន៕